**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្ដីការគណៈរដ្ឋមន្ត្រី**
**លេខ ៖** ១៨៨.ភផណ.សប

ថ្ងៃ សុក្រ ១៤រោច ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**
**សូមជម្រាបជូន**

- **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
- **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាប**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន**
- **ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តសៀមរាប**
- **ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់**
- **ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង**
- **ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង**
- **ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ**
- **ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ**

**កម្មវត្ថុ ៖** ករណីអំពីការចុះបញ្ជីដីតំបន់ទន្លេសាបស្ថិតក្នុងភូមិសាស្ត្រខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង កំពង់ធំ បន្ទាយមានជ័យ និងខេត្តសៀមរាប។

**យោង ៖**
- លិខិតលេខ២២៣ ដនស/អរប ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៤ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លិខិតលេខ០២៧ ខន/០២៤ សជណ ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៤ របស់ខុទ្ទកាល័យសម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៤។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្ដីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមជ្រាបថា រាជរដ្ឋាភិបាលសម្រេចដូចខាងក្រោម៖

១- ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធដឹកនាំចុះបញ្ជីដីរដ្ឋ និងដីឯកជនរបស់ប្រជាពលរដ្ឋ។

២- ជូនអាជ្ញាធរទន្លេសាប ពង្រឹងការអនុវត្តភារកិច្ចស្របតាមសមត្ថកិច្ចកំណត់ និងជំរុញបញ្ចប់ការធ្វើបច្ចុប្បន្នភាពផែនទីតំបន់១ តំបន់២ និងតំបន់៣ នៃតំបន់ទន្លេសាប និងធ្វើការបោះបង្គោលព្រំស្របតាមលក្ខណៈបច្ចេកទេស។

៣- ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ធ្វើបច្ចុប្បន្នភាពផែនទីដែនដលផលនៃតំបន់ទន្លេសាប។

៤- ជូនក្រសួងបរិស្ថាន ធ្វើបច្ចុប្បន្នភាពផែនទីដែនបរិស្ថាននៃតំបន់ទន្លេសាប។

៥- ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បង្កើតគណៈកម្មការចំពោះកិច្ចចុះបញ្ជីដីតំបន់ទន្លេសាប។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមជ្រាបនិងចាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**ឈួន សុធី**

**ចម្លងជូន៖**

- ក្រសួងមហាផ្ទៃ
- ក្រសួងអធិការកិច្ច
- ក្រសួងអភិវឌ្ឍន៍ជនបទ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ឯកសារ កាលប្បវត្តិ